**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** :............១៤៥.............**ក.ប**/ប្រ.ក

# ប្រកាស
# ស្តីពី
# ការកែសម្រួលការបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការបញ្ចប់តំណែងរាជរដ្ឋាភិបាល និងតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់នីតិកាលទី៥ នៃរដ្ឋសភា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការបញ្ចប់តំណែងអនុរដ្ឋលេខាធិការគ្រប់រូប និងតែងតាំងឥស្សរជនចំនួន ២៣៥រូប ជាអនុរដ្ឋលេខាធិការ នៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៨៦ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣ ស្តីពីការតែងតាំងលោកជំទាវ សៅ ស្រីពៅ ជាអនុរដ្ឋលេខាធិការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤០៤ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការតែងតាំងឯកឧត្តម ផេង សុខាំ ជាអនុរដ្ឋលេខាធិការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ-បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ-បក ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងប្រកាសលេខ២៦៩ កប/ប្រក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១.- អំពីការបែងចែកភារកិច្ច**

ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ឆ្នាំ២០១៤-២០១៨ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា ក៏ដូចជាដើម្បីឱ្យស្របតាមការតែងតាំងឯកឧត្តម និងលោកជំទាវអនុរដ្ឋលេខាធិការថ្មី ថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានកែសម្រួលភារកិច្ចក្នុងការដឹកនាំការងារដូចខាងក្រោម៖

១- **ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រី** ជាប្រធានស្ថាប័នទទួលបន្ទុកដឹកនាំគ្រប់គ្រងការងាររួមរបស់ក្រសួង និងមានភារកិច្ចទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី និងស្ថាប័ននីតិបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ដោយធ្វើការពិនិត្យសម្រេចចុងក្រោយលើរាល់ឯកសារគោលនយោបាយ និងផែនការយុទ្ធសាស្ត្ររបស់ក្រសួង ជាពិសេសដឹកនាំផ្ទាល់លើការតាមដានការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល និងកម្មវិធីការងាររបស់ក្រសួង ព្រមទាំងទទួលបន្ទុកផ្ទាល់លើការងារចាត់តាំងបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីភ្នំពេញ និងក្រុមទី២៤ (តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ) នៃក្រុមអធិការកិច្ចការងារតែមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

២- **ឯកឧត្តម ពេជ សោភ័ន រដ្ឋលេខាធិការ** មានភារកិច្ចជួយរដ្ឋមន្ត្រីដឹកនាំការធ្វើគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ និងការងាររបស់គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា ព្រមទាំងជួយរដ្ឋមន្ត្រីក្នុងការដឹកនាំការងារ៖

- អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម (ក្រៅពីទីផ្សារការងារនៅប្រទេសម៉ាឡេស៊ី និងបណ្តាប្រទេសអារ៉ាប់)
- គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស
- ក្រុមទី១៨ និងទី២០ នៃក្រុមអធិការកិច្ចការងារតែមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប
- និងភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៣- **ឯកឧត្តម អូស្មាន ហាស្សាន់ រដ្ឋលេខាធិការ** មានភារកិច្ចជួយរដ្ឋមន្ត្រីសិក្សាស្រាវជ្រាវ និងពង្រីកទីផ្សារការងារនៅប្រទេសម៉ាឡេស៊ី និងបណ្តាប្រទេសអារ៉ាប់ដែលមានបរិយាកាស និងលក្ខខណ្ឌការងារល្អព្រមទាំងជួយរដ្ឋមន្ត្រីក្នុងការដឹកនាំការងារ៖

- អគ្គាធិការដ្ឋាន
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម លើកម្មវិធីអភិវឌ្ឍន៍ទីផ្សារការងារនៅប្រទេសម៉ាឡេស៊ី និងបណ្តាប្រទេសអារ៉ាប់
- ក្រុមទី៣ និងទី៤ នៃក្រុមអធិការកិច្ចការងារតែមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ និងខេត្តកោះកុង
- និងភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៤- **ឯកឧត្តម ភាន់ ម៉ន រដ្ឋលេខាធិការ** មានភារកិច្ចជួយរដ្ឋមន្ត្រីទទួលបន្ទុកសិក្សាស្រាវជ្រាវ និងចងក្រងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍បេឡាជាតិរបបសន្តិសុខសង្គម ព្រមទាំងជួយរដ្ឋមន្ត្រីដឹកនាំការងារ៖

- ក្រុមប្រឹក្សាបច្ចេកទេសនៃបេឡាជាតិរបបសន្តិសុខសង្គម

- នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក (ក្រៅពីការងារចាត់តាំងបុគ្គលិក) និងចុះហត្ថលេខាលអាណត្តិបើកប្រាក់បៀវត្ស
- ក្រុមទី៥ និងទី៦ នៃក្រុមអធិការកិច្ចការងារតែមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តតាកែវ ខេត្តកំពត និងខេត្តកែប
- និងភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៥- **លោកជំទាវ ស៊ើង សរសុចិត្តា រដ្ឋលេខាធិការ** មានភារកិច្ចជួយរដ្ឋមន្ត្រីដឹកនាំការស្រាវជ្រាវចងក្រងវិធីសាស្ត្រ និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រទៅក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងពង្រឹងយន្តការគាំពារកុមារចេញឱ្យផុតពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ព្រមទាំងជួយរដ្ឋមន្ត្រីលើការងារៈ

- នាយកដ្ឋានការងារកុមារ
- អនុគណៈកម្មការពលកម្មកុមារ
- ក្រុមការងារយេនឌ័រ
- ក្រុមទី៧ និងទី៨ នៃក្រុមអធិការកិច្ចការងារតែមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ខេត្តស្វាយរៀង ខេត្តព្រៃវែង និងខេត្តឧត្តមានជ័យ
- និងភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៦- **ឯកឧត្តម អ៊ុំ មាន រដ្ឋលេខាធិការ** មានភារកិច្ចជួយរដ្ឋមន្ត្រីដឹកនាំការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ ភាពសុខដុមនីយកម្មសង្គម និងការងាររបស់គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា ព្រមទាំងជួយរដ្ឋមន្ត្រីដឹកនាំការងារៈ

- នាយកដ្ឋានអធិការកិច្ចការងារ
- នាយកដ្ឋានវិវាទការងារ
- រួមជាមួយ ឯកឧត្តម ពេជ សោភ័ន ទទួលបន្ទុកដឹកនាំការងារ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម (ក្រៅពីទីផ្សារការងារនៅប្រទេសម៉ាឡេស៊ី និងបណ្តាប្រទេសអារ៉ាប់)
- រួមជាមួយ ឯកឧត្តម ពេជ សោភ័ន ទទួលបន្ទុកដឹកនាំការងាររបស់គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស
- ក្រុមទី៩ និងទី១០ នៃក្រុមអធិការកិច្ចការងារតែមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះវិហារ ខេត្តកំពង់ធំ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ
- និងភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៧- **ឯកឧត្តម ហ៊ុយ ហានសុខ រដ្ឋលេខាធិការ** មានភារកិច្ចជួយរដ្ឋមន្ត្រីដឹកនាំការសិក្សាស្រាវជ្រាវ និងចងក្រងផែនការយុទ្ធសាស្ត្រស្តីពីការពង្រឹងសុវត្ថិភាពការងារ ការកំណត់មុខសញ្ញា និងប្រភេទជំងឺវិជ្ជាជីវៈ ព្រមទាំងជួយរដ្ឋមន្ត្រីដឹកនាំការងារៈ

- នាយកដ្ឋានពេទ្យការងារ
- គណៈកម្មការសម្របសម្រួលត្រីភាគីដើម្បីទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍-ជំងឺអេដស៍
- គណៈកម្មការប្រយុទ្ធនឹងជំងឺអេដស៍
- ក្រុមទី១១ និងទី១២ នៃក្រុមអធិការកិច្ចការងារតែមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគីរី និងខេត្តមណ្ឌលគីរី
- និងភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៨- **ឯកឧត្តម ម៉ម វណ្ណៈ រដ្ឋលេខាធិការ** មានភារកិច្ចជួយរដ្ឋមន្ត្រីដឹកនាំការងារផ្នែកសហប្រតិបត្តិការអន្តរជាតិ ពិសេសជាមួយអង្គការពលកម្មអន្តរជាតិ ព្រមទាំងជួយរដ្ឋមន្ត្រីក្នុងការដឹកនាំៈ

- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
- ក្រុមការងារអន្តរជាតិវិស័យការងារ
- ក្រុមទី១៣ និងទី១៤ នៃក្រុមអធិការកិច្ចការងារតែមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង
- និងភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៩- **ឯកឧត្តម ទុយ ស៊ីផាន់ អនុរដ្ឋលេខាធិការ** ជាជំនួយការឱ្យរដ្ឋមន្ត្រី និងមានភារកិច្ចជួយរដ្ឋលេខាធិការក្នុងការដឹកនាំការងារៈ

- អគ្គាធិការដ្ឋាន
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- ក្រុមទី១៥ នៃក្រុមអធិការកិច្ចការងារតែមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តរតនគិរី ខេត្តមណ្ឌលគិរី និងខេត្តស្ទឹងត្រែង
- និងភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

១០- **ឯកឧត្តម ឡេង សៃ អនុរដ្ឋលេខាធិការ** ជាជំនួយការឱ្យរដ្ឋមន្ត្រី និងមានភារកិច្ចជួយរដ្ឋលេខាធិការក្នុងការដឹកនាំការងារៈ

- នាយកដ្ឋានអធិការកិច្ចការងារ
- ក្រុមទី១៦ នៃក្រុមអធិការកិច្ចការងារតែមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង និងខេត្តបាត់ដំបង
- និងភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

១១- **ឯកឧត្តម សាត សមុទ្រ អនុរដ្ឋលេខាធិការ** ជាជំនួយការឱ្យរដ្ឋមន្ត្រី និងមានភារកិច្ចជួយរដ្ឋលេខាធិការក្នុងការដឹកនាំការងារៈ

- នាយកដ្ឋានវិវាទការងារ
- គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា
- លេខាធិការដ្ឋានគណៈកម្មការប្រឹក្សាការងារ
- ក្រុមទី១៧ នៃក្រុមអធិការកិច្ចការងារតែមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីភ្នំពេញ និងខេត្តកណ្តាល
- និងភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

១២- **ឯកឧត្តម ហ៊ូ ខុន្នី អនុរដ្ឋលេខាធិការ** ជាជំនួយការឱ្យរដ្ឋមន្ត្រី និងមានភារកិច្ចជួយរដ្ឋលេខាធិការក្នុងការដឹកនាំការងារៈ

- នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម
- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
- ការងារពាក់ព័ន្ធជាមួយនឹងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងកិច្ចប្រជុំប្រចាំឆ្នាំរបស់អង្គការអន្តរជាតិខាងការងារ
- ក្រុមទី១ នៃក្រុមអធិការកិច្ចការងារតែមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ និងខេត្តកំពង់ធំ
- និងភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

១៣- **ឯកឧត្តម ប៉ុក ប៉ាន់ អនុរដ្ឋលេខាធិការ** ជាជំនួយការឱ្យរដ្ឋមន្ត្រី និងមានភារកិច្ចជួយរដ្ឋលេខាធិការក្នុងការដឹកនាំការងារៈ

- អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ក្រុមទី១៩ នៃក្រុមអធិការកិច្ចការងារតែមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប
- និងភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**១៤- ឯកឧត្តម ចាប ឫទ្ធី អនុរដ្ឋលេខាធិការ** ជាជំនួយការឱ្យរដ្ឋមន្ត្រី និងមានភារកិច្ចជួយរដ្ឋលេខាធិការក្នុងការដឹកនាំការងារ៖

- នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
- នាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ
- ក្រុមទី២ នៃក្រុមអធិការកិច្ចការងារតែមួយ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តតាកែវ ខេត្តកំពត និងខេត្តកែប
- និងភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**១៥- លោកជំទាវ សួស រដ្ឋាវី អនុរដ្ឋលេខាធិការ** ជាជំនួយការឱ្យរដ្ឋមន្ត្រី និងមានភារកិច្ចជួយរដ្ឋលេខាធិការក្នុងការដឹកនាំការងារ៖

- នាយកដ្ឋានការងារកុមារ
- អនុគណៈកម្មការពលកម្មកុមារ
- ក្រុមការងារយេនឌ័រ
- ក្រុមទី២១ នៃក្រុមអធិការកិច្ចការងារតែមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ
- និងភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**១៦- លោកជំទាវ សៅ ស្រីពៅ អនុរដ្ឋលេខាធិការ** ជាជំនួយការឱ្យរដ្ឋមន្ត្រី និងមានភារកិច្ចជួយរដ្ឋលេខាធិការក្នុងការដឹកនាំការងារ៖

- នាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម
- ក្រុមទី២២ នៃក្រុមអធិការកិច្ចការងារតែមួយ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្វាយរៀង និងខេត្តព្រៃវែង
- និងភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**១៧- ឯកឧត្តម ផេង សុខាំ អនុរដ្ឋលេខាធិការ** ជាជំនួយការឱ្យរដ្ឋមន្ត្រី និងមានភារកិច្ចជួយរដ្ឋលេខាធិការក្នុងការដឹកនាំការងារ៖

- នាយកដ្ឋានពេទ្យការងារ
- គណៈកម្មការសម្របសម្រួលត្រីភាគីដើម្បីទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍-ជំងឺអេដស៍
- គណៈកម្មការប្រយុទ្ធនឹងជំងឺអេដស៍
- ក្រុមទី២៣ នៃក្រុមអធិការកិច្ចការងារតែមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ និងខេត្តកោះកុង
- និងភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ២.- អំពីនីតិវិធី និងការកំណត់របៀបរបបធ្វើការងារ**

ក. រាល់ឯកសារដែលទទួលពីក្រសួង ស្ថាប័ន សមាគម អង្គការជាតិ និងអន្តរជាតិត្រូវចូលតាមច្រកនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក រួចបញ្ជូនទៅខុទ្ទកាល័យរដ្ឋមន្ត្រី ដើម្បីធ្វើចំណាត់ការបន្ត។

ខ. រាល់ឯកសារដែលអង្គភាពក្រោមឱវាទ ក្នុងនោះរួមទាំងបេឡាជាតិរបបសន្តិសុខសង្គម និងគ្រឹះស្ថានសាធារណៈនៅក្រោមឱវាទក្រសួងដែលមានបំណងស្នើសុំគោលការណ៍ ឬស្នើសុំអនុសាសន៍ណែនាំ ឬស្នើសុំការពិនិត្យ និងសម្រេចរបស់រដ្ឋមន្ត្រី ត្រូវចូលតាមច្រកខុទ្ទកាល័យរដ្ឋមន្ត្រី ដោយត្រូវភ្ជាប់មកជាមួយនូវកំណត់បង្ហាញសង្ខេបរឿង និងមានការផ្តល់មតិទៅតាមឋានានុក្រមនៃការបែងចែកភារកិច្ច។

គ. រដ្ឋលេខាធិការផ្តល់យោបល់ជូនរដ្ឋមន្ត្រី ចំពោះការងារដែលបានប្រគល់ឱ្យទទួលបន្ទុក និងពិនិត្យផ្តល់យោបល់លើការងាររបស់អង្គភាពដែលខ្លួនទទួលបន្ទុក ដើម្បីផ្តល់មតិជូនរដ្ឋមន្ត្រីពិនិត្យសម្រេច។ រដ្ឋលេខាធិការអាចចុះហត្ថលេខាលើលិខិត និងឯកសារដែលខ្លួនទទួលបន្ទុកតាមការប្រគល់សិទ្ធិរបស់រដ្ឋមន្ត្រី។

ឃ. អនុរដ្ឋលេខាធិការ ផ្តល់យោបល់ជូនរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការទទួលបន្ទុក ចំពោះការងារដែលបានប្រគល់ឱ្យជួយដឹកនាំ និងពិនិត្យផ្តល់យោបល់លើការងាររបស់អង្គភាពជំនាញដែលខ្លួនទទួលបន្ទុក ដើម្បីលើកមតិជូនរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការទទួលបន្ទុកបន្តពិនិត្យសម្រេច។

ង. រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ត្រូវទទួលអនុវត្តភារកិច្ចបន្ថែមទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រី។

ច. ក្នុងពេលអវត្តមានរបស់រដ្ឋមន្ត្រី រដ្ឋមន្ត្រីនឹងផ្ទេរសិទ្ធិជូនរដ្ឋលេខាធិការ ០១រូប ជារដ្ឋមន្ត្រីស្តីទីតាមគោលការណ៍រួមរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥ នៃរដ្ឋសភា។

ឆ. ក្នុងករណីដែលថ្នាក់ដឹកនាំរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការទទួលបន្ទុកណាម្នាក់អវត្តមានលើសពី ០២ថ្ងៃ ឡើងទៅត្រូវចារថា "អវត្តមាន" ឬ "បេសកកម្ម" ត្រង់ប្រអប់ដែលថ្នាក់ដឹកនាំរូបនោះទទួលបន្ទុក រួចបញ្ជូនបន្តទៅកាន់ខុទ្ទកាល័យរដ្ឋមន្ត្រី ដើម្បីចាត់ការបានទាន់ពេលវេលា។

ជ. រដ្ឋមន្ត្រីចេញបញ្ជាដឹកនាំតាមរយៈរដ្ឋលេខាធិការទទួលបន្ទុក ឬអនុរដ្ឋលេខាធិការទទួលបន្ទុក ឬបញ្ជាត្រង់ទៅអគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន ឬនាយកដ្ឋានជំនាញត្រង់តែម្តងនូវការងារដែលចាំបាច់ និងបន្ទាន់។ អគ្គនាយក អគ្គាធិការ ឬប្រធាននាយកដ្ឋានត្រូវគោរពអនុវត្តតាម និងរាយការណ៍តាមឋានានុក្រមនូវការងារដែលខ្លួនបានទទួលបំពេញ។ ក្នុងករណីចាំបាច់ និងបន្ទាន់ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីដោយផ្ទាល់ជាមុនដើម្បីបានចាត់ការទាន់ពេលវេលា រួចជូនដំណឹងតាមឋានានុក្រមជាក្រោយ។

ឈ.គ្រប់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងគ្រប់អង្គភាពក្រោមឱវាទក្រសួងត្រូវរៀបចំសេចក្តីសម្រេចស្តីពីការបែងចែកភារកិច្ច ការកំណត់នីតិវិធី របៀបរបបបំពេញការងារ និងចរន្តលំហូរឯកសារឱ្យបានច្បាស់លាស់ជាពិសេសត្រូវកំណត់ថេរវេលានៃការបញ្ជូនឯកសារ ដែលស្ថិតក្នុងដែនអនុវត្តន៍របស់ខ្លួនបន្តទៅឋានានុក្រមបន្ទាប់ឱ្យបានច្បាស់លាស់បើទោះបីជាខ្លួនមិនឯកភាពលើសំណើ ឬសេចក្តីព្រាងនោះក៏ដោយ។

**ប្រការ៣.- របបប្រជុំ**

រដ្ឋមន្ត្រីដឹកនាំការប្រជុំប្រចាំឆមាស និងប្រចាំឆ្នាំ ជាមួយរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ថ្នាក់អគ្គនាយក អគ្គាធិការ និងថ្នាក់នាយកដ្ឋាន។ ថ្នាក់ដឹកនាំមន្ទីរ និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្រោមឱវាទក្រសួងត្រូវចូលរួមប្រជុំប្រចាំឆមាស និងប្រចាំឆ្នាំជាមួយរដ្ឋមន្ត្រីផងដែរ។ ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីអាចចាត់រដ្ឋលេខាធិការម្នាក់ដឹកនាំការប្រជុំជំនួស។ រដ្ឋមន្ត្រីអាចកោះប្រជុំវិសាមញ្ញ ហើយចំនួនអ្នកចូលរួមនឹងត្រូវកំណត់ដោយរដ្ឋមន្ត្រី។

រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការដែលទទួលបន្ទុកត្រូវដឹកនាំការប្រជុំប្រចាំត្រីមាស ឬពេលវេលាសមស្របណាមួយជាមួយអង្គភាពជំនាញដែលខ្លួនទទួលបន្ទុក ដើម្បីពិនិត្យតាមដានការអនុវត្តការងាររបស់អង្គភាពនោះ។

អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងនាយកដ្ឋាន ក៏ដូចជាអង្គភាពក្រោមឱវាទក្រសួង ក្នុងនោះរួមទាំងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្រោមឱវាទក្រសួងផងដែរ ត្រូវយកចិត្តទុកដាក់រៀបចំឱ្យមានរបបប្រជុំ និងរបាយការណ៍ជាទៀងទាត់ ដើម្បីផ្តល់ជាធាតុចូលដល់ថ្នាក់ដឹកនាំដែលទទួលបន្ទុក។

**ប្រការ៤.-**

ប្រកាស សេចក្តីសម្រេច និងលិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥.-**

ឯកឧត្តម លោកជំទាវ ដែលមានឈ្មោះក្នុងប្រការ១ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់ប្រធាននាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ